ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

លេខ : ៨៣ ក.ជ.ក.ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៦

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត មកលើកុមារ

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ/បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញអនុស្សរណៈចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការយោគយល់រវាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអង្គការអន្តរជាតិខាងការងារ
- យោងតាមសំណូមពរការងាររបស់ក្រសួង

## សំរេច

**ប្រការ ១:-** បង្កើតអនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងគោលបំណងធានាកិច្ចអនុវត្តន៍ ការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ

លើគោលនយោបាយទាំងឡាយ និងកម្មវិធីដែលទាក់ទងទៅនឹងពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ។

**ប្រការ ២:**- អនុគណៈកម្មការនេះនឹងបំពេញមុខងារជាក្រុមការងារជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣:**- អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត មកលើកុមារមានភារកិច្ចដូចតទៅ:

- ធ្វើការពិគ្រោះយោបល់លើប្រភេទ និងទំហំនៃសកម្មភាពដែលត្រូវអនុវត្តក្នុងគំរោងកម្មវិធីជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ដោយផ្អែកលើគោលនយោបាយ និងបទប្បញ្ញត្តិជាតិដែលពាក់ព័ន្ធ
- ជ្រើសរើសកម្មវិធីសកម្មភាពដែលស្នើឡើងដោយស្ថាប័នរដ្ឋាភិបាល សមាគម អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដើម្បីស្វែងរកជំនួយឧបត្ថម្ភគាំទ្រការលុបបំបាត់ពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ
- ផ្តល់ព័ត៌មាន និងយុត្តិកម្មស្តីពីកម្មវិធី និងថវិកាតាមកាលកំណត់ច្បាស់លាស់ និងតាមការស្នើសុំរបស់អង្គការ ភ្នាក់ងារ ឬ ឯកត្តជនផ្តល់ជំនួយនានា
- ពិនិត្យឡើងវិញនូវរាល់កម្មវិធីដែលកំពុងដំណើរការក្នុងក្របខ័ណ្ឌនៃកម្មវិធី ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ក្នុងបរិបទកម្មវិធីជាតិទាំងមូល
- ធ្វើការពិភាក្សា និងសម្របសម្រួលរាល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាពលកម្មកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយធ្វើកិច្ចសហការជាមួយអ្នកដើរតួនាទីសំខាន់ៗ ក្នុងដំណោះស្រាយបញ្ហាពលកម្មកុមារ
- រាយការណ៍ជាប្រចាំជូនទៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីគោលនយោបាយ កម្មវិធីផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងបញ្ហាពលកម្មកុមារ។

**ប្រការ ៤:**- សមាសភាពនៃអនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមាររួមមាន:

| | | | |
|---|---|---|---|
| ១- | **លោកជំទាវ ប្រាក់ ចន្ថា** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- | **ឯកឧត្តម ហ៊ុយ ហានសុង** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |

៣- **លោក វេង ហៀង** ប្រធាននាយកដ្ឋានការងារកុមារ **លេខាធិការអចិន្ត្រៃយ៍**

៤- **ឯកឧត្តម កែវ បូរេន្ទ្រ** អគ្គនាយកបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៥- **លោក ហោ សារុន** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ សមាជិក

៦- **លោក ហាស់ ប៊ុនថុន** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ សមាជិក

៧- **លោក ជន សូតឹម** ប្រធាននាយកដ្ឋានយុវជន នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨- **លោកវរសេនីយ៍ឯក ច័ន្ទ វណ្ណៈ** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជននៃក្រសួងមហាផ្ទៃ សមាជិក

៩- **លោកស្រី សាខឿន សាវ៉ាត់ឌី** អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី សមាជិក

១០- **លោក កែវ សេដ្ឋា** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ សមាជិក

១១- **លោក ស៊ី ច័ន្ទតារា** អនុប្រធាននាយកដ្ឋានព័ត៌មានក្នុងនិងក្រៅប្រទេស នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជានៃក្រសួងព័ត៌មាន សមាជិក

១២- **លោកស្រី តេង យូគី** អនុប្រធាននាយកដ្ឋានសុខភាពជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៣- **លោក រ៉ិត ភួងបញ្ញោ** មន្ត្រីសំរបសំរួលគំរោងរបស់សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា សមាជិក

១៤- **លោក ជួន មុំថុល** ប្រធានសហព័ន្ធសហជីពខ្មែរ និងជាប្រធាន (**PACT**) សមាជិក

១៥- **លោកប្រធាន** តំណាងអង្គការក្រៅរដ្ឋាភិបាល (**NGO-CRC**) សមាជិក

**ប្រការ ៥**:- តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងបណ្តាឯកត្តជនដែលចាប់អារម្មណ៍អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់អនុគណៈកម្មការ ។

**ប្រការ ៦**:- អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយនៅនាយកដ្ឋានការងារកុមារ ចំណុះឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៧**:- តួនាទី និង ភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នឹងត្រូវកំណត់ដោយអនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ។

**ប្រការ ៨**:- អនុគណៈកម្មការជាតិពលកម្មកុមារ មានថវិកាមួយដោយឡែក ដែលបានមកពីការជួយឧបត្ថម្ភគាំទ្រដោយអង្គការ ភ្នាក់ងារ ឬ ឯកត្តជនផ្តល់ជំនួយនានា ហើយបច្ចុប្បន្ននេះជាឧបសម្ព័ន្ធថវិការបស់នាយកដ្ឋានការងារកុមារនិងឧបត្ថម្ភគាំទ្រដោយអង្គការអន្តរជាតិខាងការងារ កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ។

**ប្រការ ៩**:- អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

**ប្រការ ១០**:- អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារមានបទបញ្ជាផ្ទៃក្នុងដោយឡែករបស់ខ្លួន ។

**ប្រការ ១១**:-រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២**:-សេចក្តីសំរេចនេះមានប្រសិទ្ធិភាពអនុវត្តន៏ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អនុគណៈកម្មការជាតិពលកម្មកុមារ**
**និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត មកលើកុមារ**
**ប្រធាន**

**ប្រាក់_ចន្ថា**

ចម្លងជូនៈ

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

-រាជកិច្ច